# សេចក្តីថ្លែងការណ៍

## ប្រជាពលរដ្ឋបានស្លាប់ និងរងរបួស ដោយសារកងកម្លាំងរបស់អាជ្ញាធរ ក្នុងអំឡុងមានភាពវឹកវរនៅក្នុងរាជធានីភ្នំពេញ

ថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤

អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ បានបញ្ជាក់ថា យ៉ាងតិចណាស់មានប្រជាពលរដ្ឋចំនួន ៤ នាក់ ត្រូវបានបាញ់សម្លាប់ ហើយ ២១នាក់ផ្សេងទៀតរងរបួស នៅក្នុងការបង្ក្រាបដោយអំពើហិង្សាយ៉ាងអាក្រក់បំផុតមកលើប្រជាពលរដ្ឋ ក្នុងរយៈពេល ១៥ ឆ្នាំមកនេះ។

ក្នុងអំឡុងពេលគ្រោះថ្នាក់នៅការកើនឡើងនៃភាពវឹកវរនៅក្នុងរាជធានីភ្នំពេញ ដែលជាលទ្ធផលនៃការបាញ់ប្រហារ អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ និងមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC) សូមធ្វើការអំពាវនាវ សូមឲ្យកងកម្លាំងប្រដាប់អាវុធ និងក្រុមបាតុករ សូមលោកមេត្តាធ្វើការអត់ធ្មត់ទាំងសងខាង ដើម្បីជៀសវាងនូវការបង្ហូរឈាមបន្តទៀត។

ណាលី ពីឡុក នាយិកាអង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ បានមានប្រសាសន៍ថា៖"យើងខ្ញុំ មានការមិនពេញចិត្តជាខ្លាំង ចំពោះការប្រើប្រាស់កងកម្លាំងហួសហេតុដោយកងសន្តិសុខ"។ អ្នកនាង បានបន្តទៀតថា៖ "កងសន្តិសុខត្រូវតែបញ្ឈប់ភ្លាមៗនូវការប្រើប្រាស់អាវុធពិតទៅលើប្រជាពលរដ្ឋសាមញ្ញ ហើយនិងធានាថាអ្នកដែលរងរបួសទាំងនោះ ត្រូវបានបញ្ជូនទៅកាន់មន្ទីរពេទ្យដោយគ្មានការពន្យាពេល"។

អ្នកឃ្លាំមើលការរំលោភសិទ្ធិមនុស្សនៃអង្គការ លីកាដូ បានឃើញហេតុការណ៍ដែលកងសន្តិសុខប្រើប្រាស់កាំភ្លើងពិតបាញ់ទៅលើប្រជាពលរដ្ឋដែលនៅក្បែរតំបន់ឧស្សាហកម្មកាណាឌីយ៉ា តាមបណ្តោយផ្លូវវេង ស្រេង នៅវេលាម៉ោង ប្រហែល ១០ ព្រឹកមិញនេះ។ ការប្រើប្រាស់កាំភ្លើងពិតនេះ ត្រូវបានប្រើប្រាស់ជាបន្តរហូតមក និងមិនមានការខិតខំប្រឹងប្រែងណាមួយ ត្រូវបានធ្វើឡើងដើម្បីការពារពីការស្លាប់ និងរងរបួសនោះទេ។ របាយការណ៍ បានបង្ហាញថា កងសន្តិសុខ ក៏ទទួលរងរបួសផងដែរ បន្ទាប់ពីបានត្រូវនឹងដុំថ្ម។

អំពើហិង្សា បានចាប់ផ្តើមឡើងនៅលើផ្លូវ វេង ស្រេង កាលពីម្សិលមិញ បន្ទាប់ពីមានការបង្ក្រាបរបស់នគរបាល និងកងរាជអាវុធហត្ថ លើកម្មករដែលតវ៉ា។ មុនពេលមានការប៉ះទង្គិចគ្នា ក្រុមកម្មករ បានប្រមូលផ្តុំគ្នា នៅលើផ្លូវដើម្បីបិទផ្លូវ ហើយដុតកង់ឡានមួយចំនួន។ ផ្លូវត្រូវបានបិទ ដោយមានការចូលឈរមើលពីប្រជាពលរដ្ឋ និងអ្នករស់នៅតាមបណ្តោយផ្លូវនោះកាន់តែច្រើនឡើងៗ។ នៅម៉ោងប្រហែល ២ ព្រឹកនៅព្រឹកមិញ កងកម្លាំងចម្រុះ បានព្យាយាមបើកផ្លូវពីក្រុមបាតុករ ប៉ុន្តែមិនទទួលបានលទ្ធផល។ អស់រយៈពេលពេញមួយថ្ងៃ កងកម្លាំងចម្រុះប្រមាណ ២០០០ នាក់ បានប៉ះទង្គិចជាមួយក្រុមបាតុករ និងធ្វើការបាញ់គ្រាប់កាំភ្លើងពិត គប់គ្រាប់បែកផ្សែង និងបាញ់ឧស្ម័នបង្ហូរទឹកភ្នែក ដែលបណ្តាលឲ្យមនុស្សជាច្រើននាក់ស្លាប់ និងរបួស។ ប្រជាពលរដ្ឋមួយចំនួន ដែលមិនទាន់ដឹងច្បាស់នូវចំនួនពិតប្រាកដ ត្រូវបានចាប់ខ្លួនមួយចំនួនទៀតបានរងរបួសយ៉ាងធ្ងន់ធ្ងរពីការវាយដំរបស់កងរាជអាវុធហត្ថ។

លោក មឿន តុលា ប្រធានកម្មវិធីការងារនៃមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ បាន មានប្រសាសន៍ថា៖ "ការវិវឌ្ឍន៍ដ៏គួរឲ្យតក់ស្លុតចុងក្រោយថ្មីៗនេះ បង្ហាញអំពីមូលហេតុដែលអាជ្ញាធរមួយចំនួនមិនអាចទ្រាំទ្រតទៅទៀតក្នុងការព្រងើយកន្តើយអំពីបញ្ហាសង្គមនានា និងល័ក្ខខ័ណ្ឌនៃការរស់នៅដ៏អាក្រក់ ដែលកម្មករកំពុងប្រឈមមុខនៅក្នុងប្រទេសកម្ពុជាសព្វថ្ងៃនេះ"។

អំពើហិង្សានាថ្ងៃនេះ បានកើតឡើងបន្ទាប់ពីការបង្ក្រាបយ៉ាងហិង្សាកាលពីម្សិលមិញ ទៅលើការតវ៉ាដោយអហិង្សា ក្នុងអំឡុងពេលមេដឹកនាំសហជីព ព្រះសង្ឃ និងកម្មករដែលធ្វើបាតុកម្ម ត្រូវបានគេវាយដំ និងចាប់ខ្លួន។ មនុស្សចំនួន ១០ នៃអ្នកដែលត្រូវបានចាប់ខ្លួនកាលពីម្សិលមិញ ត្រូវបានបញ្ជូនទៅកាន់សាលាដំបូងរាជធានីភ្នំពេញនាព្រឹកនេះ។ អ្នកទាំងនោះ ត្រូវបានចោទប្រកាន់ពីបទល្មើសនៃមាត្រា ២១៨ និង ៤១៤ នៃក្រមព្រហ្មទណ្ឌ ហើយត្រូវបានបញ្ជូនទៅកាន់មណ្ឌលអប់រំកែប្រែទី១ (ពន្ធនាគារព្រៃស)។ អ្នកទាំងនោះ ប្រឈមមុខនឹងការជាប់ឃុំឃាំងបណ្ដោះអាសន្នរង់ចាំសវនាការចំនួន ១៨ ខែ និងជាប់ពន្ធនាគារចំនួនរហូតដល់ ៥ឆ្នាំ និងពិន័យជាប្រាក់ចំនួនពី ១០០០ ដុល្លារ ទៅ ២៥០០ ដុល្លារ។ ក្រុមគ្រូពេទ្យ និងមេធាវី នៃអង្គការ លីកាដូ ត្រូវបានបដិសេធក្នុងការចូលជួបអ្នកទាំងនោះនៅទីបញ្ជាការដ្ឋានយោធាលេខ ៩១១ ជាកន្លែងដែលអ្នកទាំងនោះត្រូវបានឃាត់ខ្លួន កាលពីយប់មិញ។ មនុស្សមួយចំនួន ត្រូវបានវាយដំយ៉ាងខ្លាំង ក្នុងអំឡុងពេលនៃការចាប់ខ្លួនរបស់អ្នកទាំងនោះ ហើយត្រូវការការព្យាបាលជាបន្ទាន់។ ព្រះសង្ឃដែលត្រូវបានចាប់ខ្លួនជាមួយអ្នកទាំងនោះ ត្រូវបានដោះលែងនាយប់នោះ។

យើងខ្ញុំ សូមអំពាវនាវដល់អាជ្ញាធរ សូមលោកមេត្តាធ្វើការស៊ើបអង្កេតដោយម៉ត់ចត់ ឆាប់រហ័ស និងឯករាជ្យទៅលើព្រឹត្តិការណ៍ថ្មីៗទាំងអស់ នៃការប្រើប្រាស់កម្លាំងច្រើនហួសហេតុ រួមទាំងអ្នកដែលបញ្ជាឲ្យមាននូវការប្រើប្រាស់កាំភ្លើងពិត និងទំហំដែលកងកម្លាំងត្រូវបានប្រើប្រាស់ ដែលសមរម្យនឹងការគម្រាមកំហែង។

បុគ្គលណាដែលរកឃើញថាជាអ្នកទទួលខុសត្រូវលើការរំលោភសិទ្ធិមនុស្ស ត្រូវតែនាំមកកាត់ទោសដោយមិនមានការពន្យាពេល ហើយផ្ដល់នូវការជួសជុលការខូចខាតដល់អ្នកដែលរងរបួស និងក្រុមគ្រួសារអ្នកដែលបានស្លាប់។

*សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖*

លោក អំ សំអាត អ្នកគ្រប់គ្រងបច្ចេកទេសស៊ើបអង្កេតនៃអង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ, ទូរស័ព្ទលេខ៖ ០១២ ៣២៧ ៧៧០
លោក មឿន តុលា ប្រធានកម្មវិធីការងារនៃមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍, ទូរស័ព្ទលេខ៖ ០៦៦ ៧៧៧ ០៥៦